


| បញ្ជីអត្ថបទ | ទំព័រ |
|---|---|
| ១. ជីវភាពរស់នៅរបស់អ្នកព្រៃភ្នំ (Livelihoods of Forest-Dependent Communities, p. 1) | ... ១ |
| ២. ជនជាតិភាគតិចមណ្ឌលគីរីព្រួយបារម្ភពីសកម្មភាពរបស់ក្រុមហ៊ុនដាំស្រល់ (Community People in Mondulkiri expressed concern over land concessions, p. 2) | ... ២ |
| ៣. បំណងប្រាថ្នារបស់ប្រជាជនឃុំដាក់ដាំ (The wish of people of Dak Dam commune, p. 4) | ... ៤ |

## ជីវភាពរស់នៅរបស់អ្នកព្រៃ

ប្រជាជនដែលរស់នៅជិត និងក្នុងតំបន់ព្រៃនៃប្រទេសកម្ពុជា ពិសេសជនអន្តោគ្រាម តែងប្រកបមុខរបរចិញ្ចឹមជីវិត ដោយពឹងផ្អែកលើការប្រមូលផល-អនុផលព្រៃឈើ និង ធ្វើកសិកម្មពនេចរ ។ ប្រជាជនទាំងនេះភាគច្រើនរស់នៅក្នុងខេត្តកំពង់ធំ ព្រះវិហារ ក្រចេះ ស្ទឹងត្រែង រតនៈគីរី មណ្ឌលគីរី ។ល។

ក្នុងចំណោមអនុផលព្រៃឈើជាច្រើន គឺមានតែជ័រទឹក(ជ័រច្បោះ) តែប៉ុណោះដែលផ្តល់ប្រាក់កំរៃច្រើនជាងគេសម្រាប់ជីវភាពរស់នៅរបស់ពួកគាត់ ។ រីឯចំការពនេចរវិញ គឺដំណាំស្រូវដែលជាប្រភេទធញ្ញជាតិដ៏សំខាន់ជាងគេ ។

ប៉ុន្តែ គួរអនិច្ចា បន្ទាប់ពីការបោះឆ្នោតជាតិឆ្នាំ១៩៩៣ ក៏កើតមានភាពអនាធិបតេយ្យព្រៃឈើ ។ ប្រជាជនបានបាត់បង់ដើមច្បោះ ដោយសារជនល្មើសមានអំណាច ជនល្មើសមានប្រាក់ និង ឈ្មួញទុច្ចរិត ។ ហេតុដូច្នេះ ជីវភាពរស់នៅរបស់ពួកគាត់ត្រូវបានធ្លាក់ចុះយ៉ាងដុនដាបជាទីបំផុត ។ រាជរដ្ឋាភិបាលបានចាត់វិធានការជាច្រើនដើម្បីទប់ស្កាត់ភាពអនាធិបតេយ្យព្រៃឈើ ដោយផ្តល់តំបន់ព្រៃឈើមួយចំនួនដាក់អោយក្រុមហ៊ុនឯកជនដេញថ្លៃដើម្បីធ្វើការការពារ និង ធ្វើអាជីវកម្មឈើជាលក្ខណៈព្រៃសម្បទាន ។ ក្រុមហ៊ុនព្រៃសម្បទានបានរាយកំលាំងការពាររបស់ខ្លួនដើម្បីឃ្លាំមើលមិនអោយប្រជាជនចេញ ចូលដោយសេរីបានដូចពេលមុនឡើយ ។ ក្រុមហ៊ុនបានកាប់ឈើគ្រប់ប្រភេទ ដោយរួមទាំងច្បោះជ័ររបស់ប្រជាជនផង ។ (តទៅទំព័រទី២)

ប្រជាជនអង្វរសុំក្រុមហ៊ុនកុំឱ្យកាប់ច្បោះជ័ររបស់ពួកគាត់ ប៉ុន្តែ កម្មករក្រុមហ៊ុនបានឆ្លើយតបថាៈ "ពួកយើងកាប់តែផ្នែកខាងលើច្បោះ ចំណែកឯច្បោះ និង គល់ឈើយើងទុកឱ្យប្រជាជនរកទទួលទានបន្តទៀត" ។ ទង្វើបែបនេះនៅតែបន្តកើតមានដដែល ។

ក្រុមហ៊ុនព្រៃសម្បទានពុំបានគិតគូរដល់គោលនយោបាយ ដែលសមស្របសម្រាប់ទប់ស្កាត់ការបាត់បង់ផលប្រយោជន៍របស់ប្រជាជន ដែលធ្វើអោយការរស់នៅរបស់ប្រជាជនកាន់តែលំបាកឡើងៗ ព្រោះពួកគាត់ត្រូវបាត់បង់មុខរបរចិញ្ចឹមជីវិតដែលទទួលបានមកពីការរកជ័រទឹក ។ ប្រជាជនត្រូវពឹងផ្អែកតែលើការបោចវល្លិ៍ ពង្រីកផ្ទៃដីកសិកម្ម ចាប់សត្វព្រៃ នេសាទបន្តិចបន្តួច ផ្លាស់ប្តូរទីលំនៅ លក់ពលកម្ម ។ល។

ការងារបោចវល្លិ៍ និង ចាប់សត្វព្រៃពុំបានផ្តល់ប្រាក់កំរៃសំរាប់ធានាការរស់នៅរបស់ប្រជាជនបានឡើយ ព្រោះធនធានធម្មជាតិទាំងនោះកាន់តែខ្សត់ទៅៗ ហើយប្រជាជនត្រូវចូលព្រៃកាន់តែជ្រៅ និង ប៉ះពាល់ដល់ច្បាប់ប្រទេសជាតិ ធនធានធម្មជាតិ និង ជីវចំរុះទៀតផង ។ ចំពោះការពង្រីកផ្ទៃដីកសិកម្មវិញបានធ្វើឱ្យប៉ះពាល់ដល់ការកាប់បំផ្លាញព្រៃឈើ ហើយផលដំណាំដែលប្រជាជនបានដាំដុះមានទិន្នផលតិចតួចណាស់ ដោយសារគ្មានបច្ចេកទេស ពឹងផ្អែកតែលើធម្មជាតិ និង មានសត្វល្អិតបំផ្លាញដំណាំច្រើន ។

**Livelihoods of Forest-Dependent Communities**

Forest-dependent, especially indigenous communities rely generally on forest and non-timber forest products and shifting cultivation for their livelihoods. Resins and rice are the main source; but being threatened due to illegal logging and careless forest concessionaires.

To keep situation under control the Royal Government of Cambodia has banned logging and to allow forest dependent communities to restore their livelihoods. The communities are allowed to form into community forestry in accordance with the sub-decree on community forest. However, the creation of community forest is hampered by the RGC's limited capacity and resources.

ដោយមានភាពអសមកម្មព្រៃឈើដូចរៀបរាប់ខាងលើ រដ្ឋាភិបាលបានធ្វើការដកហូតព្រៃសម្បទានមួយចំនួនធំមកធ្វើជាសម្បត្តិរដ្ឋវិញ និង ទប់ស្កាត់អនាធិបតេយ្យព្រៃឈើ ព្រមទាំងបានចេញអនុក្រឹត្យមួយស្តីពីការបង្កើតសហគមន៍ព្រៃឈើ កាលពីខែធ្នូ ឆ្នាំ២០០៣ ក្នុងគោលបំណងផ្តល់សិទ្ធិជូនប្រជាជនរស់នៅជិតនិងក្នុងព្រៃឈើឱ្យពួកគាត់បានចូលរួមការពារធនធានធម្មជាតិ និង ប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព ក៏ដូចជាដើម្បីជួយឱ្យពួកគាត់បានស្តារជីវភាពរស់នៅឡើងវិញ ។ ប៉ុន្តែដោយសាររដ្ឋាភិបាលមានការខ្វះខាតធនធានមនុស្ស និងថវិកា ដំណើរការរៀបចំសហគមន៍ព្រៃឈើបានប្រព្រឹត្តទៅដោយលំបាក និង មានការយឺតយ៉ាវជាទីបំផុត ។

## ជនជាតិភាគតិចមណ្ឌលគិរីព្រួយបារម្ភពីសកម្មភាព របស់ក្រុមហ៊ុនដាំស្រល់

ក្រុមហ៊ុនដាំស្រល់ដែលគេជឿថាជាក្រុមហ៊ុនចិនបានចាប់ផ្តើមសកម្មភាពរបស់ខ្លួនលើដីសម្បទាន មួយកន្លែងដែលស្ថិតនៅក្នុងខេត្តមណ្ឌលគិរី ។ គ្មាននរណាម្នាក់ដឹងច្បាស់ថាតើក្រុមហ៊ុនមួយនេះទទួលបានដីសម្បទានពីពេលណា និង ទំហំប៉ុណ្ណាឡើយ ។ មិនខុសពីដីសម្បទាន និង ព្រៃសម្បទានមុនៗឡើយ ដីសម្បទានមួយនេះបាន ធ្វើឱ្យប្រជាជនមូលដ្ឋានភ្ញាក់ផ្អើលហើយថែមទាំងគ្របដណ្តប់ដល់តំបន់ដី ដែលប្រជាជនតែងតែប្រើប្រាស់កន្លងមកសំរាប់ការចិញ្ចឹមជីវិតទៀតផង ។

ថ្មីៗនេះក្រុមហ៊ុនបានចាប់ផ្តើមដំណើរការវិនិយោគដីសម្បទាននេះ ដោយបាញ់ថ្នាំពុលសម្លាប់ស្មៅ និង កាប់ដើមឈើដែលមានស្រាប់យ៉ាងគគ្រឹកគគ្រេង ។ ប្រជាជននៅមូលដ្ឋានដែលជាជនជាតិភាគតិចមានការខ្វាយខ្វល់យ៉ាងខ្លាំងអំពីបញ្ហានេះព្រោះពួកគាត់ស្តាយស្រណោះនឹងការបាត់បង់ដើមឈើ ព្រមទាំងការបំពុលដល់បរិស្ថានរស់នៅរបស់ពួកគាត់ ដែលបង្កឡើងដោយថ្នាំពុល ។

**Community people in Mondulkiri expressed concern over land concession**

Seven indigenous communities in Mondulkiri expressed their concern over the practice of a land concessionaire at a district workshop held on 26 October 2004 in O Raing district.

They were not aware that land in their area was granted as a concession until the concessionaire started spraying herbicide to get rid of weeds and logging down standing forests for pine plantation. The communities requested that the RGC help to stop the application of herbicide as it pollutes streams on which wild animals and they rely and that the concessionaire have appropriate plan to avoid taking their land and destroying their livelihoods.

នៅពេលជួបជុំគ្នាក្នុងកិច្ចប្រជុំពិភាក្សាថ្នាក់ស្រុកនៅក្នុងស្រុកអូររាំង នៃខេត្តមណ្ឌលគិរីកាលពីថ្ងៃ២៦ ខែតុលា ឆ្នាំ២០០៤ ប្រជាជនមកពីភូមិចំនួន៧ របស់ស្រុកអូររាំង បានសំណូមពរឱ្យរដ្ឋាភិបាលជួយធ្វើយ៉ាងណាសម្របសម្រួលឱ្យក្រុមហ៊ុនបញ្ឈប់រាល់ការប្រើប្រាស់ថ្នាំពុល ដែលវាអាចហូរចូលទៅក្នុងទឹកអូរនានាដែលពួកគាត់ និង សត្វព្រៃប្រើប្រាស់ ព្រមទាំងសុំឱ្យក្រុមហ៊ុនមានផែនការត្រឹមត្រូវសំរាប់គម្រោងដីសម្បទាននេះ ដោយធ្វើយ៉ាងណាកុំឱ្យបំពានលើដីភូមិ ដីអារក្ស និង ដីចំការ ដែលពួកគាត់ធ្លាប់បានប្រើប្រាស់ និង កំពុងប្រើប្រាស់ដើម្បីចិញ្ចឹមជីវិតសព្វថ្ងៃ ។

# បំណងប្រាថ្នារបស់ប្រជាជនឃុំដាក់ដាំ

ឃុំដាក់ដាំមានភូមិទាំងអស់ចំនួន ៣ភូមិ ដែលមានប្រជាជនសរុបចំនួន ១៩.៥០០ នាក់ ក្នុងនោះស្ត្រីមានចំនួន ៧.៥១៦ នាក់ ។ ភាគច្រើនលើសលប់នៃប្រជាជនក្នុងឃុំជាជនជាតិព្នងដែលជាម្ចាស់ទឹកម្ចាស់ដីដោយពួកគាត់ធ្លាប់រស់នៅទីនោះតាំងពីយូរលង់ណាស់មកហើយ ។ ប្រជាជនឃុំដាក់ដាំទាំងមូលប្រកបមុខរបរចិញ្ចឹមជីវិតដោយការធ្វើចំការពនេចរ និង ចំការស្ថិតស្ថេរ ដូចជាការដាំស្រូវចំការ, ដំឡូងមី, សណ្តែកសៀង និង ស្វាយចន្ទីជាដើម ។ ការប្រកបមុខរបរសំខាន់មួយទៀតគឺការជីកមើមរំដេង, បោចវល្លិ៍, រកឃ្មុំ, រកថ្នាំបុរាណជាដើម ។ល។ ការដាំដុះដំណាំកសិកម្មរបស់ប្រជាជនឃុំដាក់ដាំក៏ដូចជាប្រជាជនក្នុងឃុំដទៃទៀតនៅក្នុងខេត្តមណ្ឌលគិរីដែរ គឺធ្វើឡើងជាលក្ខណៈយថាផលដោយពុំមានការគាំទ្របច្ចេកទេសពីភ្នាក់ងារកសិកម្មឡើយ ។ ហេតុដូច្នោះ ផលដំណាំដែលប្រជាកសិករទទួលបានមានតិចតួច និងធ្វើអោយក៏រិតជីវភាពរបស់ពួកគាត់ត្រូវពឹងពាក់ទាំងស្រុងទៅលើអនុផលព្រៃឈើ ។

ជាអកុសលមុខរបររកផល-អនុផលព្រៃឈើរបស់ប្រជាជន បានជួបប្រទះនូវការលំបាកដោយសារការ ធ្វើអាជីវកម្មព្រៃឈើខុសច្បាប់នៅតែកើតមានជាបន្តឥតឈប់ឈរ ។ បើទោះបីជាមានការដាក់វិធានការទប់ស្កាត់ និង ហាមប្រាមយ៉ាងតឹងរឹងពីរាជរដ្ឋាភិបាល និង ក្រសួងកសិកម្មយ៉ាងណាក៏ដោយ ជនល្មើសនៅតែលបឆ្មក់លួចកាប់ឈើនិងធ្វើអាជីវកម្មឈើជាបន្តដោយឥតខ្លាចញញើត ។ ការប្រព្រឹត្តល្មើសនេះបានធ្វើឱ្យប្រជាជនជនជាតិភាគតិចកាន់តែមានការលំបាកខ្លាំងឡើងថែមទៀតក្នុងការប្រកបរបរចិញ្ចឹមជីវិត ។ម្យ៉ាងវិញទៀត ការផ្លាស់ប្តូរទីលំនៅរបស់ប្រជាជនកម្ពុជាពីដំបន់វាលទំនាបដើម្បីទៅរកដីធ្លីប្រកបរបរចិញ្ចឹមជីវិតបានធ្វើឱ្យមានការលំបាកថែមមួយកម្រិតទៀត ដោយបង្កឱ្យមានបញ្ហាជម្លោះដីធ្លី ។ កង្វះការយល់ដឹងអំពីច្បាប់ ធ្វើឱ្យមានការប្រឈមមុខជាច្រើនរវាងអាជ្ញាធរ, ប្រជាជនមូលដ្ឋាន និង ប្រជាជនដែលមកតាំងទីលំនៅថ្មី ។ (តទៅទំព័រទី៥)

**The Wish of People of Dak Dam Commune**

Phnong ethnic minority, the majority and indigenous group in Dak Dam commune, relies on swidden agriculture and collection of NTFPs. But, these very livelihoods are threatened by illegal logging and arrival of lowland communities in search of land for their own livelihoods. Despite effort of the RGC and the Ministry of Agriculture, Forestry and Fisheries to ban and crackdown on logging the problem persists.

To safeguard and use their natural resources – forest and land – in a sustainable manner and maintain them for their future generations the Dak Dam's people have wanted to set up their natural resources community in accordance with the forest and land law; but no agencies have been willing to assist. Only until recently the USAID has supported their effort and a project through ARD Inc. and ABiC, which has been implemented by SSP.

ដើម្បីថែរក្សាធនធានធម្មជាតិ និង ដីធ្លីដែលសហគមន៍ធ្លាប់បានប្រើប្រាស់ឱ្យមាននិរន្តរភាព ប្រជាជន និង ក្រុមប្រឹក្សាឃុំដាក់ដាំ បានស្វះស្វែងរកជំនួយឧបត្ថម្ភដើម្បីរៀបចំចងក្រងសហគមន៍ព្រៃឈើ ។ ប៉ុន្តែពុំមានស្ថាប័នណាស្ម័គ្រចិត្តជួយឡើយ ទើបតែថ្មីៗនេះប៉ុណ្ណោះទើបមានអង្គការUSAIDរបស់សហរដ្ឋអាមេរិកបានជួយឧបត្ថម្ភជាថវិកាតាមរយៈការគាំទ្របច្ចេកទេសពីអង្គការARD Inc. និង ABiC ដោយមានអង្គការSSPជាអ្នកអនុវត្ត ។ ប្រជាជនឃុំដាក់ដាំចង់បង្កើតជាសហគមន៍ឱ្យស្របទៅតាមច្បាប់ព្រៃឈើ និង ច្បាប់ភូមិបាល ដើម្បីពួកគាត់អាចប្រើប្រាស់ធនធានធម្មជាតិដែលពួកគាត់ធ្លាប់បានប្រើប្រាស់តាំងពីដូនតារបស់ពួកគាត់មកនោះឱ្យបានល្អប្រសើរ និង បានគង់វង្សសម្រាប់កូនចៅជំនាន់ក្រោយរបស់ពួកគាត់ ។

